- គណបក្ស សញ្ជាតិកម្ពុជា ត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមរបស់ព្រះគ្រូមហាថេរៈ លោកតាហង្ស ភ្នំត្បែងមានជ័យ។

- គណបក្ស សញ្ជាតិកម្ពុជាមានសញ្ញាព្រះអាទិត្យនិងព្រះចន្ទជួបគ្នាមានបាវចនា សញ្ជាតិ សាសនា អធិបតេយ្យមានលំដាប់លេខរៀងទី១នៅក្នុងសន្លឹកឆ្នោត។

អត្ថន័យនៃសញ្ញាសំគាល់ **គណបក្ស សញ្ជាតិកម្ពុជា** :

-ព្រះអាទិត្យ និង ព្រះចន្ទ ជួបគ្នាតំណាងឱ្យការរួបរួម គ្រប់ស្រទាប់ប្រជារាស្ត្ររស់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់រើសអើងនិន្នាការនយោបាយ ជំនឿសាសនា និងជាតិសាសន៍ ឱ្យតែអ្នកទាំងនោះ ត្រូវបានទទួលស្គាល់ដោយច្បាប់សញ្ជាតិនិងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

-ព្រះអាទិត្យពណ៌មាសនិងព្រះចន្ទពណ៌ប្រាក់តំណាងឱ្យ លទ្ធិប្រជាធិបតេយ្យ សន្តិភាព និង សហប្រតិបត្តិការរបស់សញ្ជាតិខ្មែរគ្រប់រូបដើម្បីការអភិវឌ្ឍ និងភាពថ្កុំថ្កើងរុងរឿង។

## សេចក្តីថ្លែងការណ៍

ដោយសារសង្គ្រាមបង្ហូរឈាមរវាងខ្មែរនិងខ្មែរអូសបន្លាយជាច្រើនទសវត្សរ៍ធ្វើឱ្យប្រជាជាតិខ្មែរស្លាប់អស់រាប់លាននាក់ ហើយស្ទើរតែផុតពូជ រីឯ ហេដ្ឋារចនាសម្ព័ន្ធលើគ្រប់វិស័យ បានធ្លាក់ចុះដល់កំរិតសូន្យ។ បន្ទុកដ៏ធ្ងន់ធ្ងរទាំងនេះ ធ្វើឱ្យយើងជួបប្រទះនូវឧបសគ្គច្រើនរាប់មិនអស់នៅក្នុងការស្តារ និងអភិវឌ្ឍប្រទេសជាតិមាតុភូមិ និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាហេតុធ្វើឱ្យភាពក្រីក្រនៅតែបន្តកើតមាននិងអត្រានៃប្រជាជនដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រនៅតែមានកំរិតខ្ពស់ និងមានលំដាប់ថ្នាក់ខ្ពស់នៅក្នុងបញ្ជីនៃប្រទេស ដែលមានការលូតលាស់តិចតួចបំផុត នៅក្នុងពិភពលោក។ ប្រទេសកម្ពុជា ជាប្រទេសមួយ ដែលធ្លាប់មានវប្បធម៌អារ្យធម៌ខ្ពង់ខ្ពស់និងកេរ្តិ៍ឈ្មោះល្បីរន្ទឺនោះ គណបក្សសញ្ជាតិកម្ពុជា យល់ឃើញថា ស្ថានភាពបច្ចុប្បន្ននេះ វាពុំទាន់ស្តែងឱ្យស័ក្តិសមទៅនឹងសេចក្តីប្រាថ្នាចង់បានរបស់ជនរួមសញ្ជាតិខ្មែរគ្រប់ៗគ្នាក៏ដូចជាគណបក្សសញ្ជាតិកម្ពុជានៅឡើយទេ។ ជាមួយគ្នានេះដែរ យើងនៅមានបញ្ហាអវិជ្ជមានខ្លះទៀតទន្ទឹមគ្នានឹងការខាតបង់ពីអតីតកាលដ៏ច្រើនសន្ធឹកសន្ធាប់ក៏នៅតែជាបញ្ហាដ៏ក្តៅគគុកដែលគណបក្ស សញ្ជាតិកម្ពុជាត្រូវតែមានចំណែកយ៉ាងសំខាន់ក្នុងការដោះស្រាយ។

ដើម្បីរួមចំណែកដោះស្រាយបញ្ហាដែលជាចំណោទចំបងជាច្រើនខាងលើ គណបក្ស សញ្ជាតិកម្ពុជាដែលមានបាវចនាសញ្ជាតិ សាសនា អធិបតេយ្យ ត្រូវប្រកាន់ជំហរបង្រួបបង្រួម ផ្សះផ្សា ឯកភាពជាតិ មិនគិតពីអតីតកាល គិតតែពីបច្ចុប្បន្ន និងអនាគត យកអតីតកាល ជាបទពិសោធន៍ ដោះស្រាយបញ្ហាតាមសន្តិវិធី គោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ គោរពសេរីភាពសាសនា ដោយមិនរើសអើងជំនឿសាសនា មិនប្រកាន់និន្នាការនយោបាយ លុបចោលទោសប្រហារជីវិត ពង្រឹងវប្បធម៌នីតិរដ្ឋ ជំរុញ និងលើកកំពស់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និង ជីវភាព

រស់នៅរបស់ប្រជាពលរដ្ឋហើយបានចាត់ទុកភាពក្រីក្រជាសត្រូវចំពោះមុខដែលត្រូវតែដោះស្រាយជាបន្ទាន់។

**ភាពក្រីក្រ**

នៅពេលដែលសង្គមជាតិមួយមានគំលាតគ្នាខ្លាំងពេករវាងអ្នកមាននិងអ្នកក្រហើយភាពក្រក្រីចេះតែអូសបន្លាយ មិនអាចធ្វើឱ្យប្រទេសជាតិនោះ រីកចំរើនទៅមុខបានទេហើយសង្គមនោះនឹងវិលទៅរកភ្លើងសង្គ្រាមកាប់សំលាប់គ្នា។ ចំណែកប្រទេសកម្ពុជាអត្រានៃប្រជាជនរស់ក្រោមបន្ទាត់នៃភាពក្រីក្រកំរិតខ្ពស់ ក្នុងចំណោមប្រទេសមានការអភិវឌ្ឍតិចតួចបំផុតនៅក្នុងពិភពលោកនោះ កំពុងស្រេកឃ្លានការអភិវឌ្ឍប្រកបដោយតម្លាភាព រវាងទីក្រុង និងជនបទ។ ម្យ៉ាងវិញទៀត កម្ពុជាជាប្រទេសកសិកម្មមានប្រជាជនដល់៨៥ភាគរយរស់ពឹងផ្អែកលើវិស័យនេះ វាជាសក្តានុពលមួយយ៉ាងសំខាន់សំរាប់ការរីកលូតលាស់សេដ្ឋកិច្ចជាតិប្រកបដោយចិរភាព។តើហេតុអ្វីបានជាភាពក្រីក្រនៅតែបន្តកើតមាន? ជាអកុសល សេចក្តីសង្ឃឹមថាកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាប្រកបដោយចិរភាពមានអត្រា៦%_ ៧%ក្នុង១ឆ្នាំ នៃផលិតផលសរុបជាពិសេសមានវិស័យបីគឺទេសចរណ៍ សំណង់ និងឧស្សាហកម្មកាត់ដេរនៅក្នុងកំណើននេះ ឥឡូវនេះត្រូវទទួលរងផលប៉ះពាល់ទៀតនៅពេលមានវិបត្តិសេដ្ឋកិច្ចសកល។

ក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រនេះ គណបក្ស សញ្ញាជាតិកម្ពុជាសូមគាំទ្រនិងសហការនូវរាល់គំនិតផ្តួចផ្តើមនិងសកម្មភាពទាំងឡាយណារបស់សហគមន៍ជាតិ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ ប្រទេសផ្តល់ជំនួយដែលមានសុចន្ទៈកាត់បន្ថយភាពក្រីក្រ និង លើកកំពស់ជីវភាពរស់នៅរបស់ប្រជារាស្ត្រកម្ពុជា ដោយមិនរើសអើងជាតិសាសន៍ និងនិន្នាការនយោបាយ។ជាមួយគ្នានេះគណបក្ស សញ្ញាតិកម្ពុជាសូមអំពាវនាវដល់ប្រជាជាតិខ្មែរទាំងអស់ទោះជា នៅក្នុងស្រុកក្តី នៅឯនាយសមុទ្រក្តី និងមហាកំលាំងចលករផ្សេងៗទៀត ដែលមានគំនិតសុទិដ្ឋិនិយមប្រកបដោយមនសិការជាតិខ្ពស់ សូមមេត្តាចូលរួមគាំទ្រ និងសហការជាមួយនឹងគណបក្ស សញ្ញាតិកម្ពុជានៅក្នុងការទប់ស្កាត់ ដោះស្រាយរាល់បញ្ហាអវិជ្ជមាន ដែលកំពុងកើតមាន ចំពោះមាតុភូមិ ប្រជាជាតិយើង និងក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យក្លាយជាអារ្យប្រទេស។ គណបក្ស សញ្ញាតិកម្ពុជា ជានិច្ចកាលគឺ ១.គាំទ្ររបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញគ្រប់កាលៈទេសៈ។ ២.គាំទ្រនិងគោរពយ៉ាងម៉ឺងម៉ាត់តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ៣.គាំទ្រនិងគោរពច្បាប់និងបទប្បញ្ញត្តិផ្សេងៗទៀតដែលមានជាធរមាន។៤.គោរពច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងគណបក្សនយោបាយ។ ៥.គោរពតាមសេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ។ ៦.ប្រកាន់ខ្ជាប់នូវគោលការណ៍លិទ្ធិប្រជាធិបតេយ្យសេរី និងពហុបក្ស។
៧.ប្រកាន់ខ្ជាប់នូវគោលការណ៍ការពារ រួមសុខរួមទុក្ខ ស្និទ្ធស្នាលស្រោចស្រង់ បំរើ និងឧបត្ថម្ភប្រជារាស្ត្រ។

| សូមបោះឆ្នោតជូន | ១ | គណបក្ស សញ្ញាតិកម្ពុជា | ✓ |
|---|---|---|---|

- គណបក្ស សញ្ជាតិកម្ពុជា ត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមរបស់ព្រះគ្រូមហាថេរៈ លោកតាហង្ស ភ្នំត្បែងមានជ័យ។

- គណបក្ស សញ្ជាតិកម្ពុជាមានសញ្ញាព្រះអាទិត្យនិងព្រះចន្ទជួបគ្នាមានបាវចនា សញ្ជាតិ សាសនា អធិបតេយ្យមានលំដាប់លេខរៀងទី១នៅក្នុងសន្លឹកឆ្នោត។

អត្ថន័យនៃសញ្ញាសំគាល់ **គណបក្ស សញ្ជាតិកម្ពុជា** :

-ព្រះអាទិត្យ និង ព្រះចន្ទ ជួបគ្នាតំណាងឱ្យការរួបរួម គ្រប់ស្រទាប់ប្រជារាស្ត្ររស់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់រើសអើងនិន្នាការនយោបាយ ជំនឿសាសនា និងជាតិសាសន៍ ឱ្យតែអ្នកទាំងនោះ ត្រូវបានទទួលស្គាល់ដោយច្បាប់សញ្ជាតិនិងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

-ព្រះអាទិត្យពណ៌មាសនិងព្រះចន្ទពណ៌ប្រាក់តំណាងឱ្យ លទ្ធិប្រជាធិបតេយ្យ សន្តិភាព និង សហប្រតិបត្តិការរបស់សញ្ជាតិខ្មែរគ្រប់រូបដើម្បីការអភិវឌ្ឍ និងភាពថ្កុំថ្កើងរុងរឿង។

## គោលនយោបាយនិងកម្មវិធីនយោបាយសំខាន់ៗ

គណបក្ស សញ្ជាតិកម្ពុជា គឺខ្មែរថ្មី ខ្មែរអធិបតេយ្យ ខ្មែរផ្តល់សេរីគឺជាទិសដៅដ៏ចំបងនៃការប្រមូលផ្តុំនៃគំនិតផ្នៃប្រឌិតប្រកបដោយសុទិដ្ឋិនិយម មនសិការជាតិរបស់សញ្ជាតិខ្មែរគ្រប់រូប គ្រប់និន្នាការនយោបាយក្នុងទិសដៅការពារទប់ស្កាត់ ដោះស្រាយរាល់បញ្ហាអវិជ្ជមានដ៏សែនគ្រោះថ្នាក់ ដែលកំពុងកើតមាននិងទៅអនាគត ចំពោះមាតុភូមិនិងប្រជាជាតិកម្ពុជា និង ក្នុងទិសដៅការអភិវឌ្ឍប្រទេសឱ្យរីកចំរើន លើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងប្រែក្លាយមាតុភូមិកម្ពុជាជាអារ្យប្រទេស។

ដើម្បីសំរេចបានទិសដៅដ៏ចំបងខាងលើ និងទទួលបាននូវការគាំទ្រ និងចូលរួមពីប្រជាពលរដ្ឋគ្រប់រូប គណបក្ស សញ្ជាតិកម្ពុជាដែលមានបាវចនា សញ្ជាតិ សាសនា អធិបតេយ្យ បានដាក់ចេញនូវគោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗ៧ខខាងក្រោមគឺ :

### ១. ការបង្រួបបង្រួម ផ្សះផ្សានិងឯកភាពជាតិ

ដើម្បីជៀសវាងការបែកបាក់សាមគ្គីផ្ទៃក្នុងនៅក្នុងសង្គមគ្រួសារខ្មែរ និងឈានដល់ការកាប់សំលាប់គ្នាដោយសារតែនិន្នាការន យោបាយផ្សេងៗគ្នា គណបក្ស សញ្ជាតិកម្ពុជា បានប្រកាន់ខ្ជាប់ គ្រប់កាលៈទេសៈ នូវគោលនយោបាយបង្រួបបង្រួមផ្សះផ្សានិងឯកភាពជាតិក្រោមដំបូលព្រះមហាក្សត្រតែមួយដែលព្រះអង្គទ្រង់គង់ជាម្លប់មិនប្រកាន់និន្នាការនយោបាយដើម្បីជាឧត្តមប្រយោជន៍ប្រជាជាតិមាតុភូមិដ៏ឧត្តុង្គឧត្តមរបស់សញ្ជាតិខ្មែរគ្រប់រូប។ នៅក្នុងគ្រប់បុព្វហេតុនៃការអភិវឌ្ឍប្រទេសជាតិ ឱ្យថ្កុំថ្កើងរុងរឿង លើកស្ទួយជីវភាពរស់នៅ របស់ប្រជាពលរដ្ឋប្រកបដោយសុភមង្គល និង ប្រែក្លាយមាតុភូមិកម្ពុជាជាអារ្យប្រទេសនោះ គណបក្ស សញ្ជាតិកម្ពុជាបានគាំទ្រ និង

គោរពយ៉ាងម៉ឺងម៉ាត់តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលមានបាវចនា ជាតិ សាសនា ព្រះមហាក្សត្រមិនឱ្យមានការលាបពណ៌ដោយសារតែហេតុផលនយោបាយនិងមនោគមវិជ្ជាពីខាងក្រៅ។ និយាយជារួម គណបក្ស សញ្ញាតិកម្ពុជា បានចាត់ទុកការបង្រួបបង្រួមផ្សះផ្សា និង ឯកភាពជាតិជាមូលដ្ឋានគ្រឹះនៃគ្រប់ដំណោះស្រាយនៃវិវាទទាំងអស់។

## ២. ការពារអធិបតេយ្យភាព បូរណភាពទឹកដី

ដោយសារសង្គ្រាមកាប់សំលាប់គ្នារវាងខ្មែរនិងខ្មែរដោយមនោគមវិជ្ជាបរទេស ធ្វើឱ្យបូរណភាពទឹកដីនៅតែជាបញ្ហាដ៏ក្តៅគគុកនៅឡើយ។ វាមានភាពស្មុគស្មាញណាស់នៅក្នុងរឿងនេះ គណបក្ស សញ្ញាតិកម្ពុជាយល់ថាត្រូវតែមានឯកភាពជាតិនៅក្នុងចំណោមអ្នកនយោបាយខ្មែរជាការចាំបាច់បំផុត មុននឹងចាប់ផ្តើមដំណោះស្រាយផ្សេងៗទៀត។ ជាបន្តបន្ទាប់គាំទ្រ និងសហការនូវគំនិតផ្តួចផ្តើម និងសកម្មភាពទាំងឡាយណា ដែលជំរុញឱ្យមានទិវារំលឹកខួបនៃការពារបូរណភាពទឹកដីនិងការចរចារជាទ្វេសមភាគីឬពហុសមភាគីក្នុងតំបន់ឬអន្តរជាតិតាមសន្តិវិធីដើម្បីប្រែក្លាយបញ្ហាព្រំដែនជាព្រំដែនសន្តិភាព។បើមិនដូចនេះទេយើងស្នើសុំឱ្យមានសន្និសីទអន្តរជាតិនៃបណ្តាប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីសស្តីពីកម្ពុជាថ្ងៃទី២៣តុលា១៩៩១ឡើងវិញនិងសូមឱ្យប្រទេសបារាំងដែលជាម្ចាស់អាណានិគមដែនដីឥណ្ឌូចិនជួយដោះស្រាយនៅក្នុងរឿងនេះឬប្តឹងទៅតុលាការអន្តរជាតិទីក្រុងឡាអេ។

## ៣.ការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីសស្តីពីកម្ពុជាថ្ងៃទី២៣ខែតុលាឆ្នាំ១៩៩១បានតំរូវឱ្យកម្ពុជាគោរពតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស។ ជាការពិតណាស់ការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យគឺជាការចាំបាច់នៅក្នុងការអភិវឌ្ឍប្រទេសឱ្យមានការរីកចំរើនល្អលាស់ប្រកបដោយចិរភាព និងធ្វើឱ្យសង្គមជាតិមួយរស់នៅប្រកបដោយសុភមង្គលនិងសេចក្តីថ្លៃថ្នូរ។គណបក្ស សញ្ញាតិកម្ពុជាត្រូវតែមានចំណែកយ៉ាងសំខាន់ដើម្បីជុំរុញឱ្យ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់។

និយាយជារួមការគោរពសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ព្រមទាំងលុបចោលទោសប្រហារជីវិតគឺជាកត្តាសំខាន់ចាំបាច់នៅក្នុងគោលនយោបាយ និងកម្មវិធីនយោបាយជាយុទ្ធសាស្ត្រ និងជាបំណងប្រាថ្នាដ៏ទទូចដែលបានដក់ជាប់នៅក្នុងផ្នត់គំនិតនៃថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់របស់គណបក្ស សញ្ញាតិកម្ពុជា។

**សូមបោះឆ្នោតជូន**

| ១ | គ.ស.ក **គណបក្ស សញ្ញាតិកម្ពុជា** | / |
|---|---|---|

- គណបក្ស សញ្ជាតិកម្ពុជា ត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមរបស់ព្រះគ្រូមហាថេរៈ លោកតាហង្ស ភ្នំត្បែងមានជ័យ។

- គណបក្ស សញ្ជាតិកម្ពុជាមានសញ្ញាព្រះអាទិត្យនិងព្រះចន្ទជួបគ្នាមានបាវចនា សញ្ជាតិ សាសនា អធិបតេយ្យមានលំដាប់លេខរៀងទី១នៅក្នុងសន្លឹកឆ្នោត។

អត្ថន័យនៃសញ្ញាសំគាល់ **គណបក្ស សញ្ជាតិកម្ពុជា :**

-ព្រះអាទិត្យ និង ព្រះចន្ទ ជួបគ្នាតំណាងឱ្យការរួបរួម គ្រប់ស្រទាប់ប្រជារាស្ត្ររស់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់រើសអើងនិន្នាការនយោបាយ ជំនឿសាសនា និងជាតិសាសន៍ ឱ្យតែអ្នកទាំងនោះ ត្រូវបានទទួលស្គាល់ដោយច្បាប់សញ្ជាតិនិងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

-ព្រះអាទិត្យពណ៌មាសនិងព្រះចន្ទពណ៌ប្រាក់តំណាងឱ្យ លទ្ធិប្រជាធិបតេយ្យ សន្តិភាព និង សហប្រតិបត្តិការរបស់សញ្ជាតិខ្មែរគ្រប់រូបដើម្បីការអភិវឌ្ឍ និងភាពថ្កុំថ្កើងរុងរឿង។

## ៤. គោលការណ៍វប្បធម៌នីតិរដ្ឋ:

វប្បធម៌នីតិរដ្ឋគឺគោលការណ៍ស្នូលនៃបណ្តាគោលការណ៍សំខាន់ៗទាំងអស់នៅក្នុងការដឹកនាំប្រទេសឱ្យក្លាយជាអារ្យប្រទេស។ នៅសម័យមហានគរប្រទេសកម្ពុជាមានកិត្តិនាមល្បីរន្ទឺទាំងនៅក្នុងតំបន់ និងពិភពលោកនោះក៏ដោយសារតែព្រះរាជា និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ទ្រង់ប្រតិបត្តិ និង អនុវត្តតាមរបបធម្មាធិបតេយ្យ ដូចគ្នាទៅនឹងបណ្តាប្រទេសដែលប្រកាន់យកការដឹកនាំតាមបែបនីតិរដ្ឋ សង្កេតឃើញថា ប្រទេសទាំងនោះមាន ការរីកចំរើនលើគ្រប់វិស័យ។ គណបក្ស សញ្ជាតិកម្ពុជា បានចាត់ទុកការលើកកំពស់វប្បធម៌នៃការគោរពច្បាប់ គឺជាកត្តាគន្លឹះនៅក្នុងការជំរុញឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយចិរភាព សមភាព និងយុត្តិធម៌។គណបក្ស សញ្ជាតិកម្ពុជាត្រូវតែមានចំណែកយ៉ាងសំខាន់ក្នុងការធានាអធិបតេយ្យនៃស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិនិងប្រព័ន្ធតុលាការឱ្យនៅដាច់ដោយឡែកពីគ្នានិងតំរូវឱ្យប្រជាពលរដ្ឋគ្រប់រូបមិនថា អ្នកតូច អ្នកធំត្រូវតែគោរពច្បាប់ គោរពតាមរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលមិនឱ្យចាត់ទុកស្ថាប័ននីតិប្បញ្ញត្តិរដ្ឋសភា ស្ថាប័នតុលាការ គ្រាន់តែជាស្ថាប័នមួយសំរាប់ប្រថាប់ត្រាឱ្យស្ថាប័ននីតិប្រតិបត្តិ មិនឱ្យមានវប្បធម៌និរទណ្ឌភាព មិនឱ្យជនល្មើស ជនឱកាសនិយមរស់នៅយ៉ាងមានសេរីភាពនៅក្រៅសំណាញ់ច្បាប់បានឡើយ។ ដើម្បីលើកកំពស់ និង ពង្រឹងការអនុវត្តគោលការណ៍នីតិរដ្ឋ គណបក្ស សញ្ជាតិកម្ពុជាទាមទារឱ្យមានការចូលរួមយ៉ាងសកម្មរបស់មហាជន ក្រសួង មន្ទីរស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិលដៃគូអភិវឌ្ឍ និងម្ចាស់ជំនួយ ឱ្យបានទូលំទូលាយក្នុងការចែករំលែកព័ត៌មាន ហើយចាត់ទុកសំលេងប្រឆាំងភាគតិចជាសំលេងដ៏ចាំបាច់សំរាប់បូកបញ្ចូល ទៅនឹងសំលេងភាគច្រើនដើម្បីធ្វើការសំរេចស្របតាមនីតិវិធីនៃច្បាប់។ ជាមួយគ្នានេះត្រូវធានាឱ្យបាននូវអធិបតេយ្យនៃអំណាចទាំងបី លើកកំពស់និងពង្រឹងការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ

បង្កើតឱ្យមានតុលាការឯករាជ្យ តុលាការឯកទេស ធានាឱ្យរដ្ឋបាលសាធារណៈមានលក្ខណៈអព្យាក្រឹត លើកកំពស់ការងារសវនកម្ម លើកកំពស់ធនធានមនុស្សផ្នែកច្បាប់លើកកំពស់សមត្ថភាពស្ថាប័នពាក់ព័ន្ធលុបបំបាត់ចោលនូវវប្បធម៌និរទណ្ឌភាព លើកកំពស់វប្បធម៌សន្តិភាពនិងវប្បធម៌គោរពច្បាប់ដោយក្នុងនោះត្រូវដាក់កម្មវិធីច្បាប់ចូលទៅក្នុងកម្មវិធីអប់រំទៅតាមកំរិតនិងផ្សព្វផ្សាយឱ្យបានទូលំទូលាយទៅក្នុងសហគមន៍និងបន្តគាំទ្រតុលាការខ្មែរក្រហម។

## ៥. ការអភិវឌ្ឍសេដ្ឋកិច្ច

ការអភិវឌ្ឍសេដ្ឋកិច្ចនិងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាកត្តាសំខាន់និងចាំបាច់សំរាប់កាត់បន្ថយភាពក្រីក្រនិងធ្វើឱ្យសង្គមជាតិមួយមានស្ថេរភាព។ដើម្បីធានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចិរភាពទាំងក្នុងពេលបច្ចុប្បន្ននិងអនាគតនិងឈានទៅកាត់បន្ថយភាពក្រីក្រ និងបំណុលបរទេសនោះវាចាំបាច់ណាស់នូវនយោបាយការបរទេសមួយប្រកបដោយភាពទន់ភ្លន់ប៉ិនប្រសប់ និងបើកចំហរជើងមេឃមិនប្រកាន់ថាប្រទេសសេរីឬ កុម្មុយនីស្តដើម្បីទទួលបានទីផ្សារធំទូលំទូលាយនិងក្រុមហ៊ុនវិនិយោគ ត្រូវធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងពិភពលោក ត្រូវធានាសន្តិសុខសុវត្ថិភាពសង្គម ស្ថេរភាពនយោបាយ ប្រកាន់ខ្ជាប់នូវវប្បធម៌នីតិរដ្ឋដោយលើកកំពស់និងពង្រឹងការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ លើកកំពស់ការកសាងសមត្ថភាពធនធានមនុស្សពិសេសជំនាញក្នុងនោះ ត្រូវលើកកំពស់ និង ពង្រឹងគុណភាពវិស័យអប់រំ និងលើកកំពស់វិស័យសុខាភិបាលលើកកំពស់ការអភិវឌ្ឍជនបទ ដោយកសាងហេដ្ឋារចនាសម្ព័ន្ធសារវន្តក្នុងនោះត្រូវស្ថាបនាផ្លូវគមនាគមន៍ទូរគមនាគមន៍ ថាមពលអគ្គិសនីលើកកំពស់វិស័យកសិកម្មដោយធ្វើទំនើបកម្មបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ដោះស្រាយបញ្ហាដីធ្លីដោយលើកកំពស់និងពង្រឹងការអនុវត្តច្បាប់ភូមិបាលដែលរដ្ឋសភាបានអនុម័តរួចហើយបញ្ហាព្រៃឈើ និងជលផល លើកកំពស់លើវិស័យរ៉ែនិងថាមពលដោយផ្តោតទៅលើការរុករក និងគ្រប់គ្រងរ៉ែប្រេងកាត និងរ៉ែផ្សេងទៀតស្ថាបនាថាមពលវារីអគ្គិសនីទាំងខ្នាតតូចនិងខ្នាតធំលើកកំពស់វិស័យទេសចរណ៍ដោយធ្វើការអភិរក្សលើរមណីយដ្ឋានប្រវត្តិសាស្ត្រនិងវប្បធម៌រមណីយដ្ឋានធម្មជាតិនិងបង្កើតរមណីយដ្ឋានថ្មីៗថែមទៀតជាមួយនឹងការលើកកំពស់ក្នុងការអភិរក្សវប្បធម៌និងបរិស្ថានធម្មជាតិដើម្បីទាក់ទាញភ្ញៀវទេសចរណ៍លើកកំពស់វិស័យឯកជន ឧស្សាហកម្ម សិប្បកម្មខ្នាតតូចមធ្យមលើកកំពស់នយោបាយយែនឌ័រលើកកំពស់សេវាសាធារណៈកាត់បន្ថយរបៀបរបបការិយាធិបតេយ្យ និងសហការជាមួយនឹងដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ ជាពិសេសប្រទេសម្ចាស់ជំនួយ។

## ៦. គោលការណ៍វប្បធម៌សន្តិភាពសន្តិសុខសុវត្ថិភាពសង្គម

ការប្រកាន់ខ្ជាប់នូវគោលការណ៍វប្បធម៌សន្តិភាព រក្សាសន្តិសុខ សុវត្ថិភាពសង្គមនិងស្ថេរភាពនយោបាយគឺជា

**សូមបោះឆ្នោតជូន** | ១ | គ.ស.ក | **គណបក្ស សញ្ជាតិកម្ពុជា** | √

- គណបក្ស សញ្ជាតិកម្ពុជា ត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមរបស់ព្រះគ្រូមហាថេរៈ លោកតាហង្ស ភ្នំត្បែងមានជ័យ។

- គណបក្ស សញ្ជាតិកម្ពុជាមានសញ្ញាព្រះអាទិត្យនិងព្រះចន្ទជួបគ្នាមានបាវចនា សញ្ជាតិ សាសនា អធិបតេយ្យមានលំដាប់លេខរៀងទី១នៅក្នុងសន្លឹកឆ្នោត។

អត្ថន័យនៃសញ្ញាសំគាល់ **គណបក្ស សញ្ជាតិកម្ពុជា :**

-ព្រះអាទិត្យ និង ព្រះចន្ទ ជួបគ្នាតំណាងឱ្យការរួបរួម គ្រប់ស្រទាប់ប្រជារាស្ត្ររស់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់រើសអើងនិន្នាការនយោបាយ ជំនឿសាសនា និងជាតិសាសន៍ ឱ្យតែអ្នកទាំងនោះ ត្រូវបានទទួលស្គាល់ដោយច្បាប់សញ្ជាតិនិងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

-ព្រះអាទិត្យពណ៌មាសនិងព្រះចន្ទពណ៌ប្រាក់តំណាងឱ្យ លទ្ធិប្រជាធិបតេយ្យ សន្តិភាព និង សហប្រតិបត្តិការរបស់សញ្ជាតិខ្មែរគ្រប់រូបដើម្បីការអភិវឌ្ឍ និងភាពថ្កុំថ្កើងរុងរឿង។

មូលដ្ឋានគ្រឹះនៃការអភិវឌ្ឍប្រទេសប្រកបដោយចិរភាពនិងមិនអាចខ្វះបានសំរាប់សង្គមជាតិខ្មែរទាំងមូល។ នៅគ្រប់ដំណោះស្រាយនៃវិវាទទាំងអស់ត្រូវប្រកាន់យកតាមសន្តិវិធីនិងនីតិវិធីនៃច្បាប់ បណ្តុះវប្បធម៌អហឹង្សាលើកកំពស់សីលធម៌សង្គមមិនរើសអើងជំនឿសាសនាទប់ស្កាត់និងលុបបំបាត់អំពើចោរកម្ម អំពើចាប់ជំរិត អំពើពាលាអាវ៉ាសែ អំពើជួញដូរមនុស្ស អំពើជួញដូរគ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់។ ការការពារសន្តិសុខ សុវត្ថភាពដល់ អ្នកវិនិយោគនិងទ្រព្យសម្បត្តិរបស់អ្នកវិនិយោគ និងការមិនដកហូតទ្រព្យសម្បត្តិបុគ្គលដែលមានបានក្នុងអតីតាល ទោះបីមានប្រភពពីណាក៏ ដោយគឺជាកត្តាសំខាន់ និងចាំបាច់ក្នុងការលើកទឹកចិត្ត និងទាក់ទាញអ្នកវិនិយោគ មករកស៊ីបណ្តាក់ទុន បង្កើតរោងចក្រ សហគ្រាសនៅក្នុងប្រទេសយើង។ ដើម្បីសំរេចគោលដៅនេះយើងត្រូវលើកកំពស់ដល់ការចូលរួមរបស់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ក្រសួងមន្ទីរ ស្ថាប័នរដ្ឋទាំងអស់ អង្គការសង្គមស៊ីវិលជាតិអន្តរជាតិ ត្រូវលើកកំពស់ សមត្ថភាពសមត្ថកិច្ចរបស់ស្ថាប័នពាក់ព័ន្ធត្រូវធ្វើការសហការនិងទំនាក់ទំនងឱ្យបានជិតស្និទ្ធពីក្រុមមួយទៅក្រុមមួយទៀតពីភូមិមួយទៅភូមិមួយទៀតពីឃុំសង្កាត់មួយទៅឃុំសង្កាត់មួយទៀតពីស្រុកខណ្ឌមួយទៅស្រុកខណ្ឌមួយទៀត ពីខេត្តក្រុងមួយទៅខេត្តក្រុងមួយទៀតពីតំបន់មួយទៅ ទៅតំបន់មួយទៀតនៅក្នុងប្រទេស។ លើសពីនេះ ត្រូវទំនាក់ទំនងល្អជាមួយប្រទេសភូមិផងរបងជាមួយជាមួយប្រទេសក្នុងតំបន់និងក្នុងពិភពលោក។

## ៧. ការពារវប្បធម៌និងបរិស្ថានធម្មជាតិ

វប្បធម៌រលំជាតិរលាយ។ ប្រទេសកម្ពុជាមានប្រវត្តិសាស្ត្រដ៏យូរលង់មកហើយ និងមានសម្បត្តិវប្បធម៌ដ៏សំបូរបែបនិងមិនអាចកាត់ថ្លៃបានក្នុងនោះសម្បត្តិវប្បធម៌ដែលមានសារសំខាន់ចាំបាច់និងត្រូវគោរពថែរក្សានោះគឺមនុស្ស

ខ្មែរមនុស្សខ្មែរ បានកសាងនូវវប្បធម៌អរិយធម៌របស់ខ្លួនមានច្រើនរាប់មិនអស់ទាំងរូបី និងអរូបីនៅលើមាតុភូមិអង្គរដ៏ស្រស់បវរនៃយើងជាពិសេសនៅសម័យមហានគរ។ វប្បធម៌ អរិយធម៌ដ៏ល្អផូរផង់ទាំងនេះ គឺជាមោទនភាពរបស់ជាតិដែលគណបក្ស សញ្ញាតិកម្ពុជាត្រូវតែមានចំណែកយ៉ាងសំខាន់និងមិនអាចខ្វះបានក្នុងការធ្វើពលិកម្មដើម្បីលើកកំពស់និងបន្តការពារឱ្យនៅគង់វង្សសំរាប់កុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយ និងបង្ហាញដល់សហគមន៍អន្តរជាតិបានស្គាល់ថាខ្មែរជាជាតិសាសន៍មួយមានវប្បធម៌អរិយធម៌របស់ខ្លួនដ៏យូរលង់មកហើយនៅលើឧបទ្វីបឥណ្ឌូចិន ។ ប្រាសាទបុរាណរាប់ពាន់ដែលមានសក្តានុពលទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិនិងរកចំណូលចូលថវិការជាតិរាប់រយលានដុល្លាក្នុងមួយឆ្នាំៗ រូបចំលាក់ដ៏មានតំលៃរូបបដិមាករ ក្បាលអ្នកតា និងវត្ថុសក្ការៈដ៏មានតំលៃផ្សេងទៀត ត្រូវបានពួកចោរទមិឡអន្តរ្លិយ បំផ្លាញ និងលួចយកទៅ ត្រូវធ្វើការអភិរក្ស និងទាមទារយកមកវិញ។ ធនធានធម្មជាតិដ៏សំបូរបែបមានព្រៃឈើ សត្វព្រៃ មច្ឆាជាតិ ត្បូងដ៏មានតំលៃ ធនធានធម្មជាតិក្នុងទឹក ក្រោមទឹក ក្នុងដីក្រោមបាតសមុទ្រ ត្រូវបានបំផ្លាញដោយចេតនាក្តីអចេតនាក្តីដែលគណបក្ស សញ្ញាតិកម្ពុជាត្រូវតែទប់ស្កាត់។ នៅមុនសម័យសង្គ្រាមព្រៃឈើគ្របដណ្តប់លើផ្ទៃដី៧០%នៃប្រទេស ត្បូងបរប៉ៃលិន មច្ឆាជាតិទឹកសាប ទឹកប្រៃ សម្បត្តិវប្បធម៌ ពិសេសប្រាសាទបុរាណ និងសម្បត្តិវប្បធម៌ដ៏មានតំលៃដែលមិនអាចកាត់ថ្លៃបានជាច្រើន ស្ទើរតែរលាយហិនហោច ជាពិសេសមនុស្សខ្មែរ ស្ទើរតែផុតពូជ ក្រោយសង្គ្រាមជាងបីទសវត្សរ៍។ដោយសារតែធនធានធម្មជាតិទាំងនោះត្រូវបានបំផ្លាញធ្វើឱ្យប្រជារាស្ត្រខ្មែរទទួលរងនូវគ្រោះមហន្តរាយស្ទើរតែរៀងរាល់ឆ្នាំជាពិសេសទឹកជំនន់ភាពរាំងស្ងួត អាកាសធាតុប្រែប្រួលនិងគ្រោះទុរ្ភិក្ស។ ជាមួយគ្នានេះដែរ វប្បធម៌បរទេសអវិជ្ជមាន អាសអាភាសពាលា អាវ៉ាសែបានហូរចូលដោយគ្មានការទប់ស្កាត់ និងត្រូវបានលើកកំពស់ បានពង្វក់យុវវ័យឱ្យភ្លើតភ្លើនភ្លេចអស់នូវប្រពៃណីយ៍ទំនៀមទំលាប់ដ៏ស្រស់ផូរផង់របស់ខ្លួន។ ដើម្បីការពារវប្បធម៌ បរិស្ថានធម្មជាតិនិងផលប៉ះពាល់អវិជ្ជមានដែលកំពុងកើតមាននាពេលបច្ចុប្បន្ននិងទៅអនាគតជាការចាំបាច់ ត្រូវតែពង្រឹងវប្បធម៌នីតិរដ្ឋ ការចូលរួមរបស់សហគមន៍ ប្រព័ន្ធផ្សព្វផ្សាយ ការចូលរួមរបស់សង្គមស៊ីវិលជាតិ អន្តរជាតិ សហការល្អជាមួយប្រទេសក្នុងតំបន់និងពិភពលោក។ គណបក្ស សញ្ញាតិកម្ពុជា ជានិច្ចកាលប្រកាន់ខ្ជាប់នូវគោលនយោបាយទាំង**៧២**ខាងលើនេះ ដែលជាត្រីវិស័យនិងជាកូនសោរគន្លឹះសំរាប់ដោះស្រាយរាល់បញ្ហាអវិជ្ជមាន និងធ្វើឱ្យប្រទេសជាតិមានការរីកចំរើនលើកស្ទួយជីវភាពរស់នៅរបស់ប្រជារាស្ត្រនិងប្រែក្លាយមាតុភូមិកម្ពុជាជាអារ្យប្រទេស។

| | | | |
|---|---|---|---|
| **សូមបោះឆ្នោតជូន** | ១ | **គណបក្ស សញ្ញាតិកម្ពុជា** | ✓ |

- គណបក្ស សញ្ជាតិកម្ពុជា ត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមរបស់ព្រះគ្រូមហាថេរ: លោកតាហង្ស ភ្នំត្បែងមានជ័យ។

- គណបក្ស សញ្ជាតិកម្ពុជាមានសញ្ញាព្រះអាទិត្យនិងព្រះចន្ទជួបគ្នាមានបាវចនា សញ្ជាតិ សាសនា អធិបតេយ្យមានលំដាប់លេខរៀងទី១នៅក្នុងសន្លឹកឆ្នោត។

អត្ថន័យនៃសញ្ញាសំគាល់ **គណបក្ស សញ្ជាតិកម្ពុជា** :

-ព្រះអាទិត្យ និង ព្រះចន្ទ ជួបគ្នាតំណាងឱ្យការរួបរួម គ្រប់ស្រទាប់ប្រជារាស្ត្ររស់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់រើសអើងនិន្នាការនយោបាយ ជំនឿសាសនា និងជាតិសាសន៍ ឱ្យតែអ្នកទាំងនោះ ត្រូវបានទទួលស្គាល់ដោយច្បាប់សញ្ជាតិនិងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

-ព្រះអាទិត្យពណ៌មាសនិងព្រះចន្ទពណ៌ប្រាក់តំណាងឱ្យ លទ្ធិប្រជាធិបតេយ្យ សន្តិភាព និង សហប្រតិបត្តិការរបស់សញ្ជាតិខ្មែរគ្រប់រូបដើម្បីការអភិវឌ្ឍ និងភាពថ្កុំថ្កើងរុងរឿង។

## ៨/ គោលនយោបាយការបរទេស

គ.ស.កប្រកាន់នូវនយោបាយផ្លូវកណ្តាលនៅក្នុងសម័យសកលភាវូបនីយកម្មកម្ពុជាទៅក្នុងតំបន់ និងសកលលោកនេះ។ យើងត្រូវការនូវនយោបាយការបរទេសមួយប្រកបដោយទេពកោសល្យខ្ពស់ ឲ្យបានទូលំទូលាយបើកចំហរជើងមេឃ មិនប្រកាន់ជាជាប្លុកលោកសេរីឬកុម្មុយនីស្ទនោះទេ ដើម្បីទទួលបានទីផ្សារធំទូលាយ។ យើងត្រូវប្រកាន់នូវជំហរ នយោបាយឯករាជ្យអព្យាក្រិត្យ និង មិនចូលបក្សសម្ព័ន្ធដែលប្រទេសយើងធ្លាប់បានអនុវត្តន៍កាលពីអតីតកាល ធ្វើឲ្យ ប្រទេសកម្ពុជាមានការរីកចំរើននិងមានកិត្តិនាមល្បីរន្ទឺទាំងនៅលើផ្ទៃរាបជាតិនិងផ្ទៃរាបអន្តរជាតិ។ យើងត្រូវការទំនាក់ទំនងការទូតជាមួយប្រទេសទាំងអស់ នៅលើសកលលោកដើម្បីទទួលបានផ្លែផ្កាទាំងខាងធនធានមនុស្សខាងបច្ចេកទេស នយោបាយ ទីផ្សារ វប្បធមិ។ យើងត្រូវការបញ្ជូននិស្សិតទៅសិក្សារៀនសូត្រនៅតាមបណ្តាប្រទេសជឿនលឿន នៅក្នុងលោក និងនាំត្រលប់មកវិញនូវធនធានមនុស្សប្រកបដោយគុណភាពចូលរួមការកសាងជាតិ។ ជាមួយគ្នានេះ យើងត្រូវការផ្សព្វផ្សាយត្រលប់ទៅវិញ នូវវប្បធមិ អរិយធមិរបស់យើង និងលក់ផលិតផលដែលផលិត បាននៅក្នុងស្រុកទៅទីផ្សារនៃបណ្តាប្រទេសទាំងនោះ។ ពិសេសជាងនេះទៅទៀត យើងមានមិត្តច្រើនប្រសើរជាងមានសត្រូវ។ ដើម្បីឲ្យគោលនយោបាយការបរទេសទទួលបានផ្លែផ្កាគួរជាទីពេញចិត្តនោះ គ.ស.កដែលមានសញ្ញាព្រះអាទិត្យនិងព្រះចន្ទជួបគ្នានិងមានលំដាប់លេខរៀងទីមួយនៅក្នុងសន្លឹកឆ្នោតបានដាក់ចេញនូវវិធានការណ៍ជាយុទ្ធសាស្ត្របន្តបន្ទាប់ដូចតទៅ៖

១.បន្តអនុវត្តន៍នយោបាយឯករាជ្យអព្យាក្រិត្យ និងមិនចូលបក្សសម្ព័ន្ធដែលជាស្នាព្រះហ័ស្ថរបស់ព្រះមហាវីរៈក្សត្រ។

២.ប្រកាន់យកនយោបាយឯករាជ្យ មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងប្រទេសដទៃដោយឈរលើគោលការណ៍ សន្តិសហវិជ្ជមាន។

៣.មិនគាំទ្រ មិនចូលរួមសម្ព័ន្ធភាពយោធាទ្វេភាគី រឺពហុភាគីណាមួយឡើយ។

៤.គាំទ្រចលនារំដោះជាតិនិងឯករាជ្យភាព។

៥.គាំទ្រនិងចូលរួមចលនាក្នុងបុព្វហេតុសន្តិភាពដែលស្នើឡើងដោយអង្គការសហប្រជាជាតិ

៦.គាំទ្រនិងចូលរួមសម្ព័ន្ធភាពសេដ្ឋកិច្ចដោយធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងក្នុងពិភពលោក។

## គោលនយោបាយជាយុទ្ធសាស្ត្រ៥ខ៖

ដើម្បីជាអត្ថប្រយោជន៍ប្រទេសជាតិនិងប្រជាជាតិខ្មែរនិងដើម្បីប្រែក្លាយមាតុភូមិកម្ពុជាឲ្យទៅជាអារ្យប្រទេសនោះ ព្រះគ្រូមហាថេរៈលោកតាហង្ស ភ្នំត្បែងមានជ័យ ដែលជាអ្នកផ្តួចផ្តើមបង្កើតគណបក្សសញ្ញាតិកម្ពុជាបានផ្តល់អនុសាសន៍ថា៖ គណបក្សសញ្ញាតិកម្ពុជាត្រូវតែប្រកាន់ខ្ជាប់នូវគោលនយោបាយជាយុទ្ធសាស្ត្រមិនងាករេ ដាច់ខាតមិនអាចខ្វះបាន៥ខទៀតដូចខាងក្រោម នូវគ្រប់សកម្មភាពរបស់ខ្លួន៖

១/ ត្រូវប្រកាន់ជំហរបង្រួបបង្រួម ផ្សះផ្សានិងឯកភាពជាតិ។

២/ មិនប្រកាន់និន្នាការនយោបាយ។

៣/ មិនប្រកាន់រើសអើងជាតិសាសន៍ និងជំនឿសាសនា។

៤/មិនត្រូវរឹបអូសទ្រព្យសម្បត្តិបុគ្គលដែលមានបានក្នុងអតីតកាលទោះបីមានប្រភពពីណាក៏ដោយ។

៥/ ធ្វើការលើកលែងទោស(នយោបាយ) លុបចោលនូវទោសប្រហារជីវិតទោះបីអ្នកទាំងអស់នោះមានបាតដៃប្រឡាក់ឈាមក៏ដោយ។

លើសពីនេះទៅទៀតថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ដ៏ដូចជាសមាជិកសមាជិកានៃគណបក្សសញ្ញាតិកម្ពុជាត្រូវប្រកាន់ខ្ជាប់នូវព្រះពុទ្ធសាសនាសីល៨(សិក្ខាបទ៨) យើងមិនត្រូវអនុវត្តន៍នូវនយោបាយទឹកឡើងត្រីស៊ីស្រមោច លុះដល់ទឹកហោចស្រមោចស៊ីត្រីនោះទេយើងត្រូវការរំងាប់ពៀរដោយការមិនចងពៀរ។ យើងត្រូវដើតាមមាគ៌ាព្រះពុទ្ធ។

| | | | |
|---|---|---|---|
| សូមបោះឆ្នោតជូន | ១ | គណបក្ស សញ្ញាតិកម្ពុជា | ✓ |